**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA
*Kingdom of Wonder*

**ក្រសួងទេសចរណ៍**

លេខ ១០៦ ប្រ.ក

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០០៩

# ប្រកាស
## ស្តីពីគំរូស្លាកសញ្ញាចំណាត់ថ្នាក់សណ្ឋាគារ
## ផ្កាយ ១ ផ្កាយ ២ ផ្កាយ ៣ ផ្កាយ ៤ និងផ្កាយ ៥

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៩ ប្រកាសឱ្យប្រើច្បាប់ ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៣៨ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០០០ ស្តីពីការកែសម្រួលមុខងារ និងភារកិច្ច និងការបង្កើតក្រុមអ្នកច្បាប់ និងនាយកដ្ឋានសហប្រតិបត្តិការ អន្តរជាតិ និងអាស៊ាន នៃក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៤ ស្តីពីចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍
- យោងប្រកាសលេខ ១០៥ ប្រ.កចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៩ ស្តីពីចំណាត់ថ្នាក់សណ្ឋាគាររបស់ក្រសួងទេសចរណ៍
- យោងសារាចរណែនាំលេខ ០០៤ ស.រ.ណ.ន ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៩ ស្តីពីការរៀបចំចំណាត់ថ្នាក់សណ្ឋាគាររបស់ក្រសួងទេសចរណ៍
- យោងតាមសំណូមពរចាំបាច់របស់ក្រសួងទេសចរណ៍

ក្នុងបំណងពង្រីកវិស័យឧស្សាហកម្មសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ និងងាយស្រួលដល់ភ្ញៀវទេសចរសម្គាល់បាននូវប្រភេទចំណាត់ថ្នាក់សណ្ឋាគារនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្រសួងទេសចរណ៍សម្រេចកំណត់អំពីខ្នាតគំរូស្លាកសញ្ញាចំណាត់ថ្នាក់សណ្ឋាគារដូចខាងក្រោម :

**១- វត្ថុធាតុដើមនៃស្លាកសញ្ញា :**

- ផ្ទៃកផ្ទៃខាងលើ : ធ្វើអំពីស្ពាន់សន្លឹកកម្រាស ០១ មីលីម៉ែត្រ

Downloaded from http://www.khmerlaws.com

- ផ្នែកទ្រនាប់ខាងក្រោម : ធ្វើពីឈើប្រណិតកម្រាស ១.៥ សម និងធំជាងសន្លឹកស្ពាន់មានហាមជុំវិញ ១.៥ សម ។

**២- ទម្រង់ស្លាកសញ្ញា :**

ទម្រង់ស្លាកសញ្ញារាងបួនជ្រុងទ្រវែងបញ្ឈរ តែជ្រុងខាងលើជាខ្សែរកោង ។

**៣- ទំហំស្លាកសញ្ញា :**

- ស្ពាន់ : មានបណ្តោយ ៣៨.០០ សម x ទទឹង ២៨.០០ សម
- ឈើប្រណិត : មានបណ្តោយ ៤១.០០ សម x ទទឹង ៣១.០០ សម

**៤- របៀបរចនាស្លាកសញ្ញា :**

ក- ផ្ទៃស្លាកសញ្ញា (ក្រៅពីរូបអង្គរ ក្បាច់ ឈ្មោះស្ថាប័ន ស៊ុមឈ្មោះសណ្ឋាគារ និងស៊ុមផ្កាយ) គឺជាផ្ទៃស្ពាន់ ។

ខ- រូបអង្គរផុសមានផ្ទៃពណ៌ស្ពាន់ ចម្រុះជាមួយផ្ទៃរលោងពណ៌ស និងមានខ្សែស្រមោលរលោងពណ៌ខ្មៅព័ទ្ធជុំវិញ ។

គ- ចម្លាក់ក្បាច់អង្គររលោងនៅតាមជ្រុងទាំងពីរនៃសន្លឹកស្ពាន់ផ្នែកខាងក្រោម លាបពណ៌ស្វាទុំ ។

ឃ-តួអក្សរអង់គ្លេស " Hotel" និងឈ្មោះសណ្ឋាគារ មានពណ៌ស្ពាន់ផុសលើស៊ុមពណ៌ទឹកប៊ិចស្រស់ ។

ង- តួរអក្សរខ្មែរ ក្រសួងទេសចរណ៍កម្ពុជា ប្រភេទតួរអក្សរមូលរលោង លាបពណ៌ទឹកប៊ិចស្រស់ ។

ច- តួអក្សរ Ministry of Tourism និង Cambodia ប្រភេទតួអក្សរពុម្ភរលោង លាបពណ៌ទឹកប៊ិចស្រស់ ។

ឆ- រូបផ្កាយកំពូលប្រាំផុសពណ៌ស្ពាន់ តំរៀបជាជួរលើស៊ុមពណ៌ទឹកប៊ិចស្រស់ ។

ជ- លេខសម្គាល់សុពលភាពសម្រាប់ពីរឆ្នាំជាលេខឡាតាំង មានផ្ទៃរលោងលាបពណ៌ក្រហម ។

**៥- អំពីទំហំរូបក្បាច់ តួរអក្សរ និងរូបផ្កាយ :**

ក- រូបអង្គរវត្ត មានទំហំ ៦១ មម x ៣៨.២៧ មម ។

ខ- រូបក្បាច់អង្គរ ទំហំ ៦៨.៦ មម x ៦៧.១ មម នៅតាមជ្រុងទាំង ២ ផ្នែកខាងក្រោម ។

គ- ស៊ុមឈ្មោះសណ្ឋាគារ ទំហំ ២០៦ x ៨៧.៣៥ មម ។

ឃ- អក្សរ "Hotel" ទំហំ ១៥១ មម x ៣៨.២ មម ។

ង- ឈ្មោះសណ្ឋាគារ ជាអក្សរឡាតាំង ទំហំអាចប្រែប្រួលទៅតាមចំនួនតួអក្សរ តែត្រូវតូចជាងអក្សរ "Hotel" ។

ច- ស៊ុមផ្កាយ : ២០៦ មម x ៥០.៧ មម ។

ឆ- រូបផ្កាយកំពូលប្រាំ ទំហំ ៣៤.៥៥ មម x ៣៤.៥៥ មម ។

ជ- លេខសុពលភាពឆ្នាំ ទំហំ ៨៥.៦៥ មម x ១១.២ មម ។

ឈ-ឈ្មោះស្ថាប័នចេញសេចក្តីសម្រេចទទួលស្គាល់ចំណាត់ថ្នាក់សណ្ឋាគារ " ក្រសួងទេសចរណ៍ " អក្សរសរសេរជាភាសាខ្មែរ ទំហំ ៥៥ មម x ៥.៧២ មម និងអក្សរ " កម្ពុជា" ទំហំ ៣២.៥ មម x ៥.៧២ មម ។

ញ-ឈ្មោះស្ថាប័នចេញសេចក្តីសម្រេចទទួលស្គាល់ចំណាត់ថ្នាក់សណ្ឋាគារ ជាភាសាអង់គ្លេស " MINISTRY OF TOURISM" ទំហំ ១១១.៤ មម x ៧.៤ មម និងអក្សរ "Cambodia" ទំហំ ៦០.៤៦មម x ៧.៤ មម ។

**៦- គំលាតរវាងជួរនិមួយៗ :**

ក/-គំលាតពីលើចុះក្រោម :

Downloaded from http://www.khmerlaws.com

- ពីគែមស្ពាន់ខាងលើ ដល់កំពូលអង្គរមានគំលាត ១០.៥ មម ។
- ពីផ្នែកខាងក្រោមអង្គរ ដល់ផ្នែកខាងលើស៊ុមអក្សរ "Hotel" មានគំលាត ១៣.៧២ មម ។
- ពីផ្នែកខាងក្រោមស៊ុមអក្សរ (Hotel) ដល់ផ្នែកខាងលើស៊ុមផ្កាយ មានគំលាត ១៥.៥ មម ។
- ពីផ្នែកខាងក្រោមស៊ុមផ្កាយ ដល់ផ្នែកខាងលើលេខឆ្នាំ មានគំលាត ២១.៣ មម ។
- ពីផ្នែកខាងក្រោមលេខឆ្នាំ ដល់ផ្នែកខាងលើអក្សរខ្មែរ "ក្រសួងទេសចរណ៍" មានគំលាត ៤២ មម ។
- ពីផ្នែកខាងក្រោមអក្សរខ្មែរ "ក្រសួងទេសចរណ៍" ដល់ផ្នែកខាងលើអក្សរ "កម្ពុជា" មានគំលាត ១២.៧៧ មម ។
- ពីផ្នែកខាងក្រោមអក្សរអង់គ្លេស " Ministry of Tourism" ដល់ផ្នែកខាងលើអក្សរ "Cambodia" មានគំលាត ១៥ មម ។
- ពីផ្នែកខាងក្រោមអក្សរកម្ពុជា និងអក្សរ Cambodia ដល់គែមស្ពាន់ខាងក្រោម មានគំលាត ៥៧.១ មម ។
- ក្បាច់អង្គរ ស្ថិតនៅជ្រុងទាំងពីរផ្នែកខាងក្រោម មានគំលាតពីគែមស្ពាន់សងខាង ៤ មម ។

ខ/-<u>គំលាតពីគែមសងខាងស្ពាន់</u> :

- រូបអង្គរ នៅចន្លោះកណ្តាល និងមានគំលាតពីគែមស្ពាន់សងខាង ១០៩.៥ មម ។
- អំពីស៊ុមអក្សរ "Hotel" នៅចន្លោះកណ្តាល និងមានគំលាតពីគែមស្ពាន់សងខាង ៣៧ មម ។
- អំពីស៊ុមផ្កាយនៅចន្លោះកណ្តាល និងមានគំលាតពីគែមស្ពាន់សងខាង ៣៧ មម ។
- អំពីលេខឆ្នាំ នៅចន្លោះកណ្តាល និងមានគំលាតពីគែមស្ពាន់សងខាង ៩៥.១៧ មម ។
- អំពីអក្សរខ្មែរ "ក្រសួងទេសចរណ៍" និងអក្សរអង់គ្លេស "Ministry of Tourism" ស្ថិតនៅចន្លោះកណ្តាលឃ្លាតពីគ្នា ៤៥ មម និងមានគំលាតពីគែមស្ពាន់សងខាង ១៤.៣ មម ។
- អំពីអក្សរខ្មែរ "កម្ពុជា" និងអក្សរអង់គ្លេស "Cambodia" ស្ថិតនៅចន្លោះកណ្តាល ឃ្លាតពីគ្នា ១០២មម ហើយអក្សរ "កម្ពុជា" មានគំលាតពីគែម ស្ពាន់ខាងឆ្វេង ៤៦.៥ មម និងអក្សរ "Cambodia" មានគំលាតពីគែមស្ពាន់ខាងស្តាំ ៣៨.៣០ មម ។

៧- រាល់ការប្រើប្រាស់ស្លាកសញ្ញាចំណាត់ថ្នាក់ខុសពីខ្នាតគំរូដូចបានលម្អិតខាងលើនឹងមិនមានការអនុញ្ញាតពីក្រសួងទេសចរណ៍ ត្រូវហាមឃាត់ និងត្រូវពិន័យអន្តរការណ៍ តាមមាត្រា ៤៨ នៃច្បាប់ស្តីពីទេសចរណ៍ ។

ថោង ខុន

<u>**កន្លែងទទួល**</u> :

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- សាលារាជធានី-ខេត្ត "ដើម្បីជូនជ្រាប"
- មន្ទីរទេសចរណ៍រាជធានី-ខេត្ត "ដើម្បីមុខការ"
- ម្ចាស់ ឬអ្នកគ្រប់គ្រងអាជីវកម្មសណ្ឋាគារ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

Downloaded from http://www.khmerlaws.com